# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៚៙៛

ក្រសួងសុខាភិបាល

# សេចក្តីណែនាំគ្រើនរំលឹករបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការបង្ការជំងឺផ្តាសាយបក្សីលើមនុស្ស និងការពុលចំណីអាហារ ឬស្រា

រដូវកាលនៃបុណ្យចូលឆ្នាំចិន និងចូលឆ្នាំខ្មែរ កំពុងតែឈានមកដល់នាពេលខាងមុខនេះ ប្រជាពលរដ្ឋជាទូទៅតែងតែមានការជួបជុំគ្នាពិសារភេសជ្ជៈ និងចំណីអាហារ ឬធ្វើដំណើរកំសាន្តសប្បាយនៅក្នុង ឬនៅក្រៅប្រទេសជាដើម។ ដើម្បីការពារលោកអ្នកឲ្យចៀសផុតពីការពុលស្រា ឬពុលចំណីអាហារ ឬការចម្លងរោគឆ្លងផ្សេងៗ ជាពិសេសដោយសារតែជំងឺផ្តាសាយបក្សីនៅតែមានចរាចរលើសត្វបសុបក្សីនៅតាមបណ្តាប្រទេសមួយចំនួន ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំគ្រើនរំលឹកជូនដល់សាធារណជនទាំងអស់នូវវិធានការសាមញ្ញ សម្រាប់ការពារលោកអ្នកពីការចម្លងរោគឆ្លងផ្តាសាយបក្សីនិងការពារការពុលចំណីអាហារ ឬស្រាដែលផលិតមិនត្រឹមត្រូវតាមបច្ចេកទេស ដោយក្រសួងសូមជម្រាបជូនថា ចាប់តាំងពីឆ្នាំ ២០០៥ រហូតមកដល់ ឆ្នាំ២០១៤ ប្រទេសកម្ពុជា ធ្លាប់មានករណីជំងឺផ្តាសាយបក្សីប្រភេទ H5N1 ចំនួន ៥៦ ករណី ដែលក្នុងនោះ ៣៧ ករណី បានស្លាប់។ ទោះជាតាំងពីពេលនោះមកដល់ពេលបច្ចុប្បន្ន ប្រទេសកម្ពុជានៅមិនទាន់មានករណីជំងឺផ្តាសាយបក្សីកើតឡើងជាថ្មីលើមនុស្សក៏ដោយ ហើយករណីពុលចំណីអាហារ និងស្រា នៅតែកើតមានឡើងជាញឹកញាប់នោះ បុគ្គលគ្រប់រូបត្រូវមានការប្រុងប្រយ័ត្នផ្ទាល់ខ្លួន ដូចខាងក្រោមនេះ៖

### ក. សម្រាប់ការពារការចម្លងជំងឺផ្តាសាយបក្សី

- គួរតែជៀសវាង ការចូលទៅកន្លែងចិញ្ចឹមសត្វ (បើគ្មានភារកិច្ច) ឬប៉ះពាល់ផ្ទាល់ជាមួយសត្វនៅតាមកសិដ្ឋានចិញ្ចឹមសត្វ និងទីផ្សារបក្សីរស់ ឬចូលកន្លែងសត្តឃាត ឬប៉ះពាល់ជាមួយផ្ទៃណាមួយដែលកខ្វក់ ឬប្រលាក់ដោយលាមកសត្វបសុបក្សី ឬសត្វដទៃទៀត
- ត្រូវលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូនិងទឹកស្អាត ព្រមទាំងប្រកាន់ខ្ជាប់នូវការអនុវត្តអនាម័យផ្ទាល់ខ្លួន និងអនាម័យចំណីអាហារដែលមានសុវត្ថិភាពល្អ។ ត្រូវចងចាំថា មិនអាចឆ្លងវីរុសផ្តាសាយបក្សីទេ បើលោកអ្នកកាន់ ឬបរិភោគបសុបក្សី និងស៊ុត ដែលចម្អិនបានល្អត្រឹមត្រូវ។
- ត្រូវយល់ដឹងថា វីរុសជំងឺផ្តាសាយបក្សី ជាធម្មតាចរាចរក្នុងចំណោមបសុបក្សី ដែលវីរុសនេះរួមមាន H5N1, H5N6, H7N3, H7N7, H7N9 និង H9N2 ហើយដែលអាចឆ្លងទៅមនុស្សបាននិងបណ្តាលឲ្យមានជំងឺផ្តាសាយបក្សី។ បច្ចុប្បន្នដោយសារតែវីរុសនៅតែបន្តចរាចរគ្មានព្រំដែនកំណត់ វាជាក្តីកង្វល់ចំពោះសុខភាពសាធារណៈនៅក្នុងប្រទេសផង ក្នុងតំបន់ផង និងជាសកលផង។ ដោយសារវីរុសនេះនៅបន្តរកឃើញនៅលើសត្វនិងក្នុងបរិស្ថាន ករណីជំងឺផ្តាសាយបក្សីនេះ អាចនឹងមានការចម្លងមកមនុស្ស ហើយអាចត្រូវបានរំពឹងទុកថា នឹងអាចកើតមានជំងឺផ្តាសាយបក្សីនេះទៀត។ តាមរយៈការសិក្សាអេពីដេមីសាស្ត្រនិងវីរុសសាស្ត្ររបស់អង្គការសុខភាពពិភពលោក បានបង្ហាញថា វីរុសនេះ មិនមានសមត្ថភាពងាយចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតនៅឡើយទេ។ រោគសញ្ញាជំងឺផ្តាសាយបក្សី មានចាប់ពីគ្រុនផ្តាសាយធម្មតាទៅជាជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ហើយអ្នកជំងឺភាគច្រើនដែលមានការឆ្លងវីរុសនេះ មានជំងឺរលាកសួតធ្ងន់ធ្ងរ។ រោគសញ្ញាទូទៅរួមមាន គ្រុនក្តៅលើសពី ៣៨,៥ អង្សាសេ ក្អក និងពិបាកដកដង្ហើម ដែលអាចឲ្យ



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ស្លាប់បាន។ ជំងឺផ្តាសាយបក្សីប្រភេទ H5N1 H7N9 និង H5N6 គ្មានវ៉ាក់សាំងសម្រាប់ការពារទេ រីឯការព្យាបាលជំងឺមិនមានថ្នាំប្រឆាំងវីរុសជាក់លាក់ទេ មានតែការព្យាបាលគាំទ្រតែប៉ុណ្ណោះ ។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា *"ជំងឺផ្តាសាយបក្សី នៅតែបន្តគំរាមកំហែងដល់សុខភាពប្រជាជននៅលើពិភពលោក និងនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ខ្ញុំសូមក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ថា ត្រូវនៅអោយឆ្ងាយពីសត្វបក្សីឈឺឬងាប់ និងត្រូវប្រាកដថា លោកអ្នកបានលាងដៃជាមួយសាប៊ូនឹងទឹកស្អាត មុនពេលបរិភោគ និងបន្ទាប់ពីបានប៉ះជាមួយសត្វបសុបក្សី។ ដៃអាចប្រលាក់ដោយវីរុស ដែលវីរុសនេះមិនអាចមើលឃើញដោយភ្នែកទទេបានទេ។ ប្រសិនបើមានករណីសង្ស័យជំងឺផ្តាសាយបក្សី លោកអ្នកត្រូវស្វែងរកការព្យាបាលជាបន្ទាន់នៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈដែលនៅជិតផ្ទះរបស់លោកអ្នក ហើយត្រូវជម្រាបជូនលោកគ្រូឬអ្នកគ្រូពេទ្យអំពីប្រវត្តិជំងឺ និងប្រវត្តិនៃការធ្វើដំណើរ ព្រមទាំងការធ្លាប់បានប៉ះពាល់ជាមួយសត្វបក្សីឈឺឬងាប់ ព្រមទាំងរោគសញ្ញាដែលកើតមាន"* ។

សារអប់រំពីរបៀបបង្ការការចម្លងជំងឺផ្តាសាយបក្សី សំខាន់ៗ រួមមាន៖

- លាងដៃអោយបានញឹកញាប់ ជាមួយសាប៊ូនិងទឹក មុនពេលបរិភោគ និងបន្ទាប់ពីប៉ះពាល់ជាមួយបសុបក្សី
- នៅឆ្ងាយពីសត្វបសុបក្សី ដាក់សត្វបសុបក្សីនៅឲ្យឆ្ងាយពីកន្លែងរស់នៅ
- កុំបរិភោគ សត្វបសុបក្សីឈឺឬងាប់ និងរាល់សត្វបសុបក្សីដែលធ្វើសំរាប់បរិភោគ ត្រូវចម្អិនអោយបានឆ្អិនល្អ។

## ២. សម្រាប់ការពារការពុលចំណីអាហារ ឬស្រាដែលផលិតមិនមានបច្ចេកទេសត្រឹមត្រូវ

ក្រសួងសុខាភិបាល សូមជម្រាបជូនសាជាថ្មីថា ករណីពុលស្រា គឺបង្កឡើងដោយសារជាតិមេតាណុល ដែលមាននៅក្នុងស្រាលើសពីកម្រិតធម្មតា (០,១៥%) ដែលមានកើតឡើងនៅច្រើនកន្លែងនៅទូទាំងពិភពលោក ដោយសារស្រាដែលផលិតឬបិត នៅតាមមូលដ្ឋានសហគមន៍មិនបានត្រឹមត្រូវតាមក្បួនខ្នាតបច្ចេកទេស។ ការពុលស្រា បណ្តាលអោយស្រវាំង ឬងងឹតភ្នែក សន្លប់ ប្រកាច់ ពិបាកដកដង្ហើម និងអាចវិវត្តទៅស្លាប់បាន។ រីឯការពុលចំណីអាហារវិញ គឺបង្កឡើងដោយសារចំណីអាហារចម្អិនមិនបានល្អ មិនស្អាត មានមេរោគ ជូរផ្អូម ឬមានសារធាតុគីមី ដែលបណ្តាលឲ្យមានបញ្ហាសុខភាពដូចជា ឈឺពោះ រាករូស និងក្អួត ជាដើម។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមណែនាំនិងលើកទឹកចិត្តគ្រប់ៗគ្នា ឲ្យចូលរួមអនុវត្តនូវវិធានការប្រុងប្រយ័ត្ន រួមទាំងការការពារផ្ទាល់ខ្លួននិងក្រុមគ្រួសាររបស់ខ្លួន ដើម្បីជៀសផុតពីបញ្ហាពុលចំណីអាហារ និងស្រាដែលផលិតមិនមានបច្ចេកទេសត្រឹមត្រូវ ដោយរួមគ្នាអនុវត្តនូវវិធានការសាមញ្ញដូចខាងក្រោមនេះ៖

***១. ការពុលចំណីអាហារ*** ៖ គឺបណ្តាលមកពីការបរិភោគចំណីអាហារមិនស្អាត ចម្អិនមិនបានឆ្អិនល្អ ឬទឹកកខ្វក់ដែលមានមេរោគ បាក់តេរី វីរុស ប៉ារ៉ាស៊ីត ឬសារធាតុគីមី។ ដើម្បីចៀសផុតពីការពុលចំណីអាហារនេះ ដែលភាគច្រើនបណ្តាលមកពីការរៀបចំទុកដាក់អាហារមិនមានអនាម័យ ឬចំអិនមិនបានល្អ ខ្ញុំសូមលើកទឹកចិត្តឲ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ គឺគ្រប់គ្នាៗចាប់តាំងពីអ្នកបរិភោគរហូតដល់អ្នកបំរើអាហារ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការលើកកម្ពស់សុវត្ថិភាពចំណីអាហារ ដោយការអនុវត្តអនាម័យចំណីអាហារល្អ លាងសំអាតចំណីអាហារនិងសំភារៈ សំរាប់ចំអិនឲ្យបានត្រឹមត្រូវមុនពេលចំអិន ឬមុនពេលបរិភោគ រក្សាសុវត្ថិភាពចំណីអាហារជានិច្ចដោយរក្សាទុកដាក់ត្រឹមត្រូវ និងចម្អិនអាហារ ឲ្យបានឆ្អិនល្អ កុំពិសារសាច់ឆៅ ឬអាហារដែលមិនឆ្អិនល្អ ឬអាហារដែលទុកយូរ និងត្រូវពិសារទឹកឆ្អិនឬទឹកស្អាតឬទឹកបរិសុទ្ធ និងត្រូវ លាងដៃឲ្យបានស្អាតជាមួយសាប៊ូ និងឲ្យបានញឹកញាប់។ ត្រូវបន្ទារបង់នៅតាមទីកន្លែងដែលមានបង្គន់អនាម័យ និងត្រូវចោលសំរាមក្នុងធុង សំរាម។

***២. ចំពោះគ្រឿងស្រវឹង*** ៖ ចំពោះមនុស្សពេញវ័យទាំងអស់ សូមពិសារគ្រឿងស្រវឹងដោយការទទួលខុសត្រូវ នៅក្នុងកំរិតតិចតួច និងហាមពិសារគ្រឿងស្រវឹងក្នុងពេលបើកបរ ឬបញ្ជាគ្រឿងម៉ាស៊ីន។ សូមប្រើកបរដោយមានការប្រុងប្រយ័ត្ន កុំ



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

បើកបរលឿនពេក និងប្រកាន់ខ្ជាប់នូវច្បាប់បើកបរ។ សូមកុំពិសារស្រាដែលផលិតមិនមានបច្ចេកទេសត្រឹមត្រូវ ឬយកមេតាណុលមកលាយធ្វើជាស្រាសដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវ ហើយបើមានរោគសញ្ញានៃការពុលស្រា ដូចជា ឈឺក្បាល ក្អួត ឈឺពោះ វិលមុខ ងងឹតភ្នែក សន្លប់ ប្រកាច់ និងពិបាកដកដង្ហើម សូមស្វែងរកការពិនិត្យព្យាបាលនិងជួយសង្គ្រោះជាបន្ទាន់នៅតាមស្តង់គ្រូពេទ្យ ប្រចាំការចល័ត ឬទៅមណ្ឌលសុខភាព ឬទៅមន្ទីរពេទ្យដែលនៅជិតលោកអ្នកបំផុត។

ក្រសួងសុខាភិបាល សូមលើកទឹកចិត្តឲ្យសាធារណជនទូទៅអនុវត្តតាមដំបូន្មានសាមញ្ញខាងលើដើម្បីការពារអ្នក និងក្រុមគ្រួសារ និងសូមជូនពរលោកអ្នកទាំងអស់គ្នា មានសុខភាពល្អសប្បាយរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំចិន និងឆ្នាំខ្មែរនាពេលខាងមុខនេះ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តនៃបញ្ហាសុខភាពតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រ នេះមានសំភារៈអប់រំសុខភាព ដែលអាចទាញយកមកមើលបាន និងហ្វេសបុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

សំរាប់ព័ត៌មានបន្ថែមៈ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនងៈ

ក្រសួងសុខាភិបាល

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩